# គំនិតទូទៅខ្លីៗរបស់មុខវិជ្ជា

១. បើអាចធ្វើទៅបាន,សូមប្រគល់ជូនការណែនាំការសិក្សាមួយថ្ងៃឬក៏ពីរថ្ងៃ មុនអ្នកចាប់ផ្តើមបង្រៀនមុខវិជ្ជានេះ ។

២. សូមប្រគល់ជូនសៀវភៅមានចំណងជើងថា *យល់ដឹងពីព្រះគម្ពីររបស់អ្នក* សរសេរដោយលោក ដេវីដ ហ្វូន ។ សូមមើលក្រដាសថតចំលងរបស់គ្រូនៃបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់ (នៅទំព័របន្ទាប់) សំរាប់កិច្ចការដែលត្រូវអានបន្ថែមពីសៀវភៅនេះ ។ អ្នកអាចជាវសៀវភៅដែលមានចំណងជើងថា *យល់ដឹងពីព្រះគម្ពីររបស់អ្នក* ពីការិយាល័យរៀបចំកម្មវិធីសិក្សានៅក្នុងមជ្ឈមណ្ឌលរបស់យើងខ្ញុំ ។

៣. នៅទំព័រទី ២ ក្នុងសៀវភៅណែនាំរបស់គ្រូ អ្នកមានបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់ ដែលបានផ្តល់ជូននូវកាលបរិច្ឆេទ នៅពេលដែលកិច្ចការត្រូវធ្វើនិមួយៗគួរតែត្រូវបានបំពេញចប់ ។ អោយពួកគេបំពេញនូវកាលបរិច្ឆេទសមរម្យដោយប្រើបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់ដែលមិនទាន់មានការសរសេរនៅទំព័រខាងក្រោយនៃ សៀវភៅការណែនាំការសិក្សារបស់ពួកគេ ។

៤. នៅទំព័រទី ១៧ ក្នុងសៀវភៅណែនាំរបស់សិស្សមានបញ្ជីនៃកណ្ឌ័គម្ពីរសញ្ញាថ្មី និង ចំនែករបស់កណ្ឌ័គម្ពីរ ។ សូមប្រាប់សិស្សអោយប្រើបញ្ជីនេះនៅពេលដែលរៀនដើម្បីធ្វើសំនួរខ្លីៗសំរាប់មុខវិជ្ជានេះ ។

៥. ពេលអ្នកបង្រៀនមុខវិជ្ជានេះ, សូមផ្តោតទៅលើថា តើហេតុអ្វីបានជាយើងមានព្រះគម្ពីរ ។

ក. ព្រះគម្ពីរមិនត្រូវបានសរសេរឡើងជាសៀវភៅប្រវត្តិសាស្រ្តនៃពិភពលោកទាំងមូលនោះទេ ។ ព្រះគម្ពីរមានពតិមានខាងប្រវត្តិសាស្រ្តជាច្រើន ។ ប៉ុន្តែ ពតិមាននេះមិនមែនជាហេតុផលដ៏សំខាន់ដែលព្រះជាម្ចាស់អោយមានព្រះគម្ពីរនោះទេ ។

ខ. ព្រះគម្ពីរមិនមែនជាសៀវភៅដែលចងក្រងឡើង ដើម្បីទស្សទាយពីអនាគតកាលនោះទេ ។

គ. ខ្ញុំចាំបាច់ត្រូវប្រើការបង្រៀននៅក្នុងព្រះគម្ពីរដើម្បីនាំអោយខ្ញុំចូលទៅជិតព្រះជាម្ចាស់ ។

ឃ. ព្រះគម្ពីរជាសៀវភៅសំរាប់ដឹកនាំខ្ញុំ ក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ ។

លើកយកចំនុច គ និង ឃ ម្តងហើយម្តងទៀតក្នុងមុខវិជ្ជាទាំងមូល ។ ចំនុចទាំងនេះអាចជួយដល់អ្នក បើសិនជាជំលោះ ឬ ការប្រកែកគ្នាកើតឡើងអំពីថាតើការបកប្រែមួយណាដែលល្អបំផុតនោះ ។

៦. ទប់ទល់នឹងការល្បួង ដើម្បីបង្រៀនអ្វីៗដែលអ្នកយល់ដឹងពីប្រធានបទនេះ ។ គោលបំណងរបស់យើងគឺមិនមែនបង្រៀនគ្រប់ទាំងសម្ភារៈដែលមុខវិជ្ជានៅក៏រិតខ្ពស់នឹងរួមបញ្ចូលនោះទេ នៅក្នុងការស្ទង់មើលនៃព្រះគម្ពីរលេខ ១០១ ។ យើងគ្រាន់តែចង់ផ្តល់នូវមូលដ្ឋានគ្រឹះ និង ប្រាប់ពួកគេនូវទិសដៅដែលពួកអាចរៀនបន្ថែមទៀតសំរាប់ខ្លួនឯងផ្ទាល់ ។

៧. គំនិតមួយដែលអាចនាំនូវភាពផ្សេងៗគ្នាជាច្រើនមុខនៅក្នុងមុខវិជ្ជានេះ គឺណែនាំអោយសិស្សស្គាល់ឧបករណ៍សិក្សា ព្រះគម្ពីរខុសគ្នាជាមួយថ្នាក់រៀននិមួយៗ ។

# បញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់

**ចំណងជើងមុខវិជ្ជា** ការមើលព្រះគម្ពីរយ៉ាងលឿន

## សំនួរខ្លីៗ

នៅកាលបរិច្ឆេទខាងក្រោម អ្នកនឹងត្រូវបានផ្តល់ជូនសំនួរខ្លីៗនៅលើឈ្មោះចំនែក ឬក៏ ក្រុម និង កណ្ឌ័គម្ពីរសញ្ញាថ្មី ។ គេនឹងផ្តល់ជូនអ្នកនូវសន្លឹកក្រដាសទទេ និង សួរអោយអ្នករាយបញ្ជីការបែងចែក និង ឈ្មោះរបស់កណ្ឌ័គម្ពីរនៅក្នុងចំនែកនិមួយៗ ។

កាលបរិច្ឆេទ_______________សំនួរខ្លីៗនៅលើគម្ពីរដំណឹងល្អ និង ប្រវត្តិក្រុមជំនុំ

កាលបរិច្ឆេទ_______________សំនួរខ្លីៗនៅលើគម្ពីរដំណឹងល្អតាមរយៈសំបុត្ររបស់លោក ប៉ូល

កាលបរិច្ឆេទ_______________សំនួរខ្លីៗនៅលើកណ្ឌ័គម្ពីរក្នុងសញ្ញាថ្មី និង ការបែងចែកទាំងអស់ ។

| **គំរោង** | **ចំណងជើង** | **កាលបរិច្ឆេទកំណត់យក** |
|---|---|---|
| ១. | កណ្ឌ័គម្ពីរដែលសរសេរដោយម៉ូសេ | ថ្ងៃ ទី ១ |
| ២. | កណ្ឌ័គម្ពីរប្រវត្តិសាស្ត្រ | ថ្ងៃ ទី ២ |
| ៣. | កណ្ឌ័គម្ពីរកំណាព្យ | ថ្ងៃ ទី ២ ឬ អាចជ្រើសរើសបាន |
| ៤. | កណ្ឌ័គម្ពីរព្យាការី(១) | អាចជ្រើសរើសបាន |
| ៥. | កណ្ឌ័គម្ពីរព្យាការី(២) | ថ្ងៃ ទី ៣ |
| ៦. | កណ្ឌ័គម្ពីរដំណឹងល្អ និង ប្រវត្តិក្រុមជំនុំ | ថ្ងៃ ទី ៤ |
| ៧. | កណ្ឌ័គម្ពីរសំបុត្រដោយ លោក ប៉ូល | អាចជ្រើសរើសបាន |
| ៨. | កណ្ឌ័គម្ពីរសំបុត្រទូទៅ និង ព្រះបន្ទូលថ្លែងទុក | ថ្ងៃ ទី ៥ |

សូមអានពីសៀវភៅ **ការយល់ដឹងពីព្រះគម្ពីររបស់អ្នក** ទំព័រ ទី ១, ៤-៧ ថ្ងៃ ទី ១

ទំព័រ ទី ៨-១១ ថ្ងៃ ទី ២

**ការប្រលង :** កាលបរិច្ឆេទ ថ្ងៃ ទី ៥

# មេរៀនទី ១ :

# ហេតុអ្វីបានជាយើងមានព្រះគម្ពីរ

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែមានការយល់ដឹងអោយបានច្បាស់លាស់ថាតើ ហេតុអ្វីបានជាយើងមានព្រះគម្ពីរ ។

## ២. ខ គម្ពីរសំខាន់ : ១ ពេត្រុស ២:២

ចូរប្រាថ្នាចង់បានព្រះបន្ទូលដូចទារកទើបនឹងកើតប្រាថ្នាចង់បានទឹកដោះសុទ្ធដើម្បីឱ្យបងប្អូនបានចំរើនឡើង តាមរយៈព្រះបន្ទូលនេះ និង ទទួលការសង្គ្រោះ ។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ៤-៧ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។

## ៤. ការចាប់ផ្តើមមេរៀន ( ៥-១០នាទី)

ចូរជ្រើសរើសសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងបួនដើម្បីណែនាំអោយស្គាល់មុខវិជ្ជានេះ ។

**ក. បង្ហាញអោយឃើញពីភាពខុសគ្នាក្នុងការបកប្រែព្រះគម្ពីរ**

បើអាចធ្វើទៅបាន សូមចំលងគម្ពីរសញ្ញាចាស់ពីភាសាហេប្រឺ និង គម្ពីរសញ្ញាថ្មីពីភាសាក្រិក ។

**ខ.** សួរសំនួរនេះ, " **បើអ្នកជាព្រះជាម្ចាស់** ,ហើយចង់សរសេរសៀវភៅសំរាប់មនុស្សនៅលើផែនដីនេះ,តើអ្នកគិតថាអ្នកគួរតែបញ្ចូលកិច្ចការសំខាន់បំផុតអ្វីនៅក្នុងសៀវភៅនេះ? អ្នកអាចពិភាក្សារួមគ្នាជាមួយនឹងសិស្សនៅក្នុងថ្នាក់អំពីសំនួរនេះ ។ ឬអ្នកអាចបំបែកគ្នាជាក្រុមតូចៗដែលមានគ្នា ពី ២-៤ នាក់ដើម្បីពិភាក្សានូវសំនួរនេះ ។

**គ. សួរសំនួរទាំងនេះ**

- តើបទពិសោធន៍កុមារភាពអ្វី អ្នកចងចាំអំពីព្រះគម្ពីរ?
- តើអ្នកមានព្រះគម្ពីរនៅផ្ទះរបស់អ្នកឬទេ?
- តើអ្នកធ្លាប់អានឬទេ?
- តើឳពុកម្តាយ និង យាយតារបស់អ្នក និយាយអ្វីឬទេអំពីព្រះគម្ពីរ?

អ្នកអាចបើកចំហរដោយលើកទឹកចិត្ត ដល់សិស្សផ្សេងៗទៀត ដើម្បីឱ្យចែកចាយ ចំលើយរបស់ពួកគេទៅនឹងសំនួរទាំងនេះជាមួយនឹងសិស្សទាំងអស់ក្នុងថ្នាក់ ។ ឬអ្នកអាចឱ្យសិស្សក្នុងថ្នាក់បំបែកគ្នាជាក្រុមតូចៗ ដែលមានគ្នា ពី ៣-៥ នាក់ហើយពិភាក្សាគ្នាអំពីសំនួរទាំងនេះ ។

## ៥. សេចក្តីពិតសំខាន់អំពីព្រះគម្ពីរ (៥-១០នាទី)

បង្រៀនចំនុច ក. " *សេចក្តីពិតសំខាន់អំពីព្រះគម្ពីរ* " ។ សូមមើលទំព័រ ទី ៥ និង ៦ នៃសៀវភៅណែនាំរបស់សិស្ស សំរាប់ពតិមាននេះ ។ បង្រៀនចំនុចដំបូង ទាំងបី ដោយសង្ខេប ។

## ៦. ភាសាដើមរបស់ព្រះគម្ពីរ (៥-១០នាទី)

ពេលណាអ្នកពិភាក្សា ពីភាសាអ្វីដែលបានសរសេរក្នុងគម្ពីរមុនគេនោះ, អ្នកអាចបង្ហាញពួកគេដោយថតចំលងពីគម្ពីរសញ្ញាចាស់ជាភាសាហេប្រឺ និង សញ្ញាថ្មីជាភាសាក្រិក ។ ប្រសិនបើអ្នកអត់មាន សូមស្វែងរកព្រះវិហារដែលនៅជិតៗ ឬ នៅសិក្ខាសាលា, ឬក៏បណ្ណាល័យសាធារណៈ ។

បើអ្នកអត់មានកណ្ឌគម្ពីរជាសាភាហេប្រឺ ឬ ក្រិកទេ, អ្នកអាចឱ្យសិស្សមើលទំព័រ ទី ៥ នៅក្នុងសៀវភៅ *យល់ដឹងពីព្រះគម្ពីររបស់អ្នក* ។ សៀវភៅនេះផ្តល់ឱ្យនៅគំរូភាសានិមួយៗ ។

សូមពន្យល់ឱ្យបានច្បាស់ថា តើហេតុអ្វីបានជាគម្ពីរសញ្ញាចាស់សរសេរជាហេប្រឺ និង គម្ពីរសញ្ញាថ្មីសរសេរជាភាសាក្រិក ។ ភាសាទាំងនេះគឺជាភាសាដែលប្រជាជនទាំងនោះប្រើក្នុងយុគសម័យដែលព្រះគម្ពីរបានសរសេរឡើង ។ នេះក៏ជាមូលហេតុដែលមានកណ្ឌគម្ពីរសញ្ញាចាស់ខ្លះត្រូវបានសរសេរជាភាសាអារ៉ាមិកផងដែរ ។

## ៧. ការបកប្រែជាភាសាអង់គ្លេសរបស់ព្រះគម្ពីរ (៥-១០នាទី)

នេះគឺជាឱកាសដ៏ល្អដើម្បីរំលឹកឡើងវិញខ្លីៗនូវចំនុចស្រដៀងៗគ្នាចំពោះការបកប្រែព្រះគម្ពីរ ។ សព្វថ្ងៃនេះ យើងមានការបកប្រែជាភាសាអង់គ្លេសជាច្រើន ។ ហេតុផលសំខាន់ៗ ដែលយើងមានជាច្រើនដូចនេះ ដោយសារអ្នកបកប្រែចង់បង្ហាញនូវការពិតនៃការបកប្រែព្រះគម្ពីរអោយមកជាភាសាសាមញ្ញ សំរាប់មនុស្សសព្វថ្ងៃនេះ ។

សូមបង្ហាញថា ព្រះគម្ពីរដើមដំបូងមិនត្រូវបានសរសេរជាភាសាអង់គ្លេសដែលគេប្រើពីប៉ុន្មានរយឆ្នាំមុននោះទេ ។ ហេតុផលដ៏សំខាន់របស់ភាសាអង់គ្លេសដែលគេសរសេរឡើងជាច្រើនរយឆ្នាំមកនោះមានការពិបាកសំរាប់មនុស្សជាច្រើនយល់នៅសព្វថ្ងៃនេះដោយសារតែ ភាសាអង់គ្លេសមានការផ្លាស់ប្តូរ។ នៅពេលដែលភាសាអង់គ្លេសដែលត្រូវបានបកប្រែជាច្រើនរយឆ្នាំមកនោះ គឺជាភាសាធម្មតាដែលមនុស្សប្រើ និង ងាយស្រួលយល់នៅជំនាន់នោះ ។

អ្នកអាចធ្វើការថតចំលងពី **សិបថកិន** (Septuagint) ជាការបកប្រែពីភាសាក្រិកនៃគម្ពីរសញ្ញាចាស់ដែលត្រូវប្រើជាទូទៅនៅក្នុងប្រទេសអ៊ីស្រាអែលក្នុងសម័យព្រះយេស៊ូ ។

សូមប្រុងប្រយត្ន័ អ្នកមិនត្រូវជាប់នៅក្នុងការពិភាក្សាបច្ចេកទេសនៃការបកប្រែនោះទេ ។ ទុកកិច្ចការនេះសំរាប់ពេលក្រោយ ។ នៅពេលនេះ យើងចង់ផ្តល់ជូននៅគំនិតដ៏ធំទូលាយអំពីព្រះគម្ពីរ ។

ការសំរេចចិត្តមួយណាជាការបកប្រែដ៏ល្អបំផុតរបស់ព្រះគម្ពីរនោះមិនមែនជាសេចក្តីពិតសំខាន់ៗនៃព្រះគម្ពីរដែលយើងទំនាក់ទំនងនៅថ្ងៃនេះក្នុងមេរៀននេះនោះទេ ។ ប៉ុន្តែផ្ទុយទៅវិញ សូមប្រើពេលវេលានេះដើម្បីបញ្ជាក់ថាតើហេតុអ្វីបានជាយើងចាំបាច់ត្រូវតែមានព្រះគម្ពីរជាភាសាផ្ទាល់ខ្លួនរបស់យើងនៅថ្ងៃនេះ ។

សូមចង្អុលបង្ហាញថា ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ច្រើន ទៅលើការដែលយើងអនុវត្តន៍សេចក្តីពិតរបស់ព្រះគម្ពីរនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ច្រើនជាងការបកប្រែប្រភេទណាមួយរបស់ព្រះគម្ពីរដែលយើងអាននោះ ។ វិធីដទៃទៀតយើងអាចនិយាយថា :

**ការបកប្រែល្អបំផុតរបស់ព្រះគម្ពីរដើម្បីប្រើគឺជាព្រះគម្ពីរដែលអ្នកអនុវត្តន៍នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នក ។**

## ៨. ភាពស៊ីសង្វាក់គ្នារបស់ព្រះគម្ពីរ និង ការបង្ហាញអោយឃើញនៅតែបន្ត (៥-១០នាទី)

បង្រៀនចំនុចខ " *ភាពស៊ីសង្វាក់គ្នារបស់ព្រះគម្ពីរ* " និង ចំនុច គ " *ការយល់ដឹងពីអត្ថន័យទាំងមូល ( ការបង្ហាញអោយឃើញនៅតែបន្ត )* ។ " សូមមើលទំព័រ ទី ៦-៧ ក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមានដើម្បីបង្ហាញ ។ អ្នកមិនចាំបាច់បង្ហាញអោយបានពិស្តារទៅលើចំនុចទាំងពីរនេះនោះទេ ។

ចំនុច គ លើកឡើងនូវបញ្ហាអោយមានការប្រុងប្រយត្ន័ អោយយល់ដឹងពីអត្ថន័យទាំងមូលនៅពេលអានអត្ថបទព្រះគម្ពីរ ។ សូមពន្យល់ដោយសង្ខេប មានបញ្ហាខ្លះដែលមកពីការ " យកផ្នែកខ្លះនៃ ខ គម្ពីរទាំងមូល " សូមពន្យល់ថាតើយើងចង់មានន័យយ៉ាងដូចម្តេចអំពីបញ្ហានេះ ។

## ៩. តើព្រះគ្រីស្ទស្របទៅតាមព្រះគម្ពីរទាំងមូលដោយរបៀបណា? (៥នាទី)

ប្រើពតិមាននៅទំព័រ ទី ៧ នៃសៀវភៅណែនាំរបស់សិស្សត្រង់ចំនុច ឃ " តើព្រះគ្រីស្ទស្របទៅតាមព្រះគម្ពីរទាំងមូលដោយរបៀបណា? " សូមឱ្យពួកគេយល់ដឹងច្បាស់ថា ការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ទគឺជាព្រឹត្តិការណ៍ដ៏សំខាន់បំផុតដែលបានកត់ត្រាចូលក្នុងគម្ពីរ ។ ផ្នែកនៃមេរៀននេះអាចត្រូវបានភ្ជាប់យ៉ាងងាយស្រួលជាមួយនឹងសេចក្តីពិតសំខាន់ៗនៃព្រះគម្ពីររបស់មេរៀននេះ ។

## ១០. ឆ្នាំត្រូវបានគេកំណត់ ឬក៏ រាប់ដោយរបៀបណា ( ៥ នាទី )

សិស្សរបស់អ្នកខ្លះ អាចមានការយល់ដឹងពីប្រវត្តិសាស្ត្របុរាណ ប៉ុន្តែមិនទូលំទូលាយនោះទេ គឺមានកំណត់ ។ វាមានការងាយស្រួលណាស់ដោយពន្យល់ថា ព្រះគម្ពីរសញ្ញាចាស់ត្រូវបានតែងឡើងមុន ព្រះយេស៊ូប្រសូត្រ និង ព្រះគម្ពីរសញ្ញាថ្មីត្រូវបានតែងឡើងបន្ទាប់ពីព្រះគ្រីស្ទប្រសូត្រមក ។ ប៉ុន្តែប្រហែលជាមានសិស្សខ្លះ មិនយល់ពីរបៀបឆ្នាំដែលត្រូវបានកំណត់ មុននឹងព្រះគ្រីស្ទប្រសូត្រនោះទេ ។

នៅពេលដែលសិស្សរបស់អ្នកសិក្សាអោយស៊ីជំរៅខាងប្រវត្តិសាស្ត្រនៃពេលវេលារបស់ព្រះគម្ពីរ ពួកគេចាំបាច់ត្រូវតែមានការយល់ដឹងអោយបានច្បាស់លាស់នៅប្រព័ន្ធនៃការកំណត់លេខ ។ សូមមើលទំព័រ ទី ៧ ក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមានបន្ថែមនៅលើចំនុចនេះ ។

## ១១. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥ នាទី)

អ្នកអាចរំលឹកសេចក្ដីពិតនៃព្រះគម្ពីរ និង ខគម្ពីរសំខាន់ៗ នៅពេលអ្នករួមបញ្ចូលមេរៀននេះ ។ អោយសិស្សម្នាក់ៗឆ្លុះបញ្ចាំងទៅលើសំនួរទាំងនេះ :

- ហេតុអ្វីបានជាព្រះប្រទានព្រះគម្ពីរដល់យើង?
- ហេតុអ្វីបានជាខ្ញុំត្រូវតែមានព្រះគម្ពីរ ?
- តើខ្ញុំមានផែនការយ៉ាងណាដើម្បីប្រើព្រះគម្ពីរក្នុងជីវិតរបស់ខ្ញុំ ?
- តើខ្ញុំនឹងឆ្លើយតបចំពោះការបង្រៀននៅក្នុងព្រះគម្ពីរដោយរបៀបណា ?

ពួកគេចាំបាច់ត្រូវតែមើលឃើញថា ព្រះគម្ពីរគឺជាសំបុត្ររបស់ព្រះជាម្ចាស់សំរាប់យើង ។ ទ្រង់នឹងមានព្រះបន្ទូលមកកាន់យើងតាមរយៈពាក្យដែលទ្រង់បានតែង ។

## ១២. កិច្ចការដែលត្រូវធ្វើ

**ក.** ផ្ដល់សំនួរ ខ្លីៗ ទី ១

**ខ.** ដាក់ពិន្ទុ គំរោង ទី ១

**គ.** ប្រសិនបើអ្នកមិនទាន់បានផ្ដល់នូវសៀវភៅណែនាំរបស់សិស្ស និង សៀវភៅណែនាំការសិក្សានៅពេលចាប់ផ្ដើមថ្នាក់រៀននោះទេ សូមប្រគល់ជូនដល់សិស្ស ។

**ឃ.** អោយសិស្សអានទំព័រ ទី ៤-៧ ក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីរំលឹកឡើងវិញប្រធានបទដែលត្រូវបានពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

**ង.** អោយសិស្សអានទំព័រ ទី ៨-១០ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដែលបានរៀបចំសំរាប់វគ្គសិក្សានៅពេលក្រោយ ។

## ១៣. ការវាយតម្លៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក?

# មេរៀន ទី ២ :

# ព្រះគម្ពីរត្រូវបានព្រះវិញ្ញាណបំភ្លឺអោយតែង

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ដោយសារតែព្រះគម្ពីរត្រូវបានព្រះវិញ្ញាណបំភ្លឺអោយតែងដោយព្រះជាម្ចាស់ ខ្ញុំចាំបាច់ត្រូវតែប្រើព្រះគម្ពីរសព្វថ្ងៃនេះទៅតាមផ្លូវដែលព្រះជាម្ចាស់ចង់អោយខ្ញុំប្រើ ។

## ២. ខ គម្ពីរសំខាន់ : ២ ធីម៉ូថេ ៣:១៦

គ្រប់អត្ថបទគម្ពីរសុទ្ធតែព្រះជាម្ចាស់ ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង និង មានប្រយោជន៍សំរាប់បង្រៀនរកខុសត្រូវ កែតំរង់ និង អប់រំឱ្យរស់តាមសេចក្តីសុចរិត ។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រទី ៨-១០ ក្នុងសៀវភៅណែនាំរបស់សិស្ស ស៊ីគ្នាជាមួយនឹងមេរៀននេះ ។

## ៤. ការចាប់ផ្តើមមេរៀន (៥នាទី)

សូមជ្រើសរើសសកម្មភាព មួយ ឬ ពីរ ដើម្បីណែនាំអោយស្គាល់មេរៀននេះ ។ បើអ្នកប្រើល្ខោនខ្លី អ្នកត្រូវតែជ្រើសរើសអ្នកចូលរួមអោយបានមុន និង ផ្តល់ជូននូវផ្នែកដែលគេត្រូវសំដែង ។

### ក. <u>សំបុត្រនៅក្នុងកាបូប</u>

អ្នកអាចបង្កើតល្បែង ប្រកួតប្រជែងមួយ ឬ ល្បែងពាក្យ ដែលមានអក្សរនៅក្នុងកាបូប ហើយច្របល់វា ។ បន្ទាប់មកចាក់វាចេញ អក្សរទាំងនេះ រាយប៉ាយមិនមាននៅតាមលំដាប់ទេ ។ សូមមើលថា តើមានប៉ុន្មាន ពាក្យ ឬ ប៉ុន្មានប្រយោគ ដែលមិនទាន់រៀបតាមលំដាប់អក្សរ នៅពេលនោះ ។ អ្នកមិនអាចរកវាឃើញទេ ។

ប្រើនូវកិច្ចការដ៏តូចនេះជាគោលដៅរបស់មេរៀន ដើម្បីបង្ហាញថា ព្រះគម្ពីរមិនបានដាក់បញ្ចូលគ្នាដោយចៃដន្យនោះទេ ។ មានអង្គតែមួយគត់បានរៀបចំផែនការនេះ និង បានប្រើមនុស្សផ្សេងៗគ្នាជាច្រើនអោយបំពេញគំរោងផែនការនេះ គឺជាព្រះជាម្ចាស់នេះឯង ។

**ខ. ល្បែងខ្លី១ សំរាប់ " អ្នកយកពតិមាន "**

ប្រាប់សិស្សឱ្យពួកគេធ្វើជាសាក្សី ក្នុងការជួបគ្នារវាងមនុស្សពីរនាក់ ។ ពួកគេសំដែងនៅលើផ្នែកអ្នកយកពតិមាន និង កត់ត្រានូវអ្វី ដែលកើតមានឡើងភ្លាម១ នៅពេលដែលឆាកសំដែងនោះបានបញ្ចប់ ។ ពួកគេមិនត្រូវប្រៀបធៀបរបាយការណ៍របស់ពួកគេរហូតដល់មនុស្សគ្រប់គ្នាបានបញ្ចប់ ។

សំរាប់ល្បែងខ្លី១ មានមនុស្សពីរនាក់ចូលមកក្នុងបន្ទប់ពីក្រុមផ្ទុយគ្នា ជួបមុខគ្នានៅខាងមុខ ។ អោយមនុស្សម្នាក់និយាយពាក្យរាក់ទាក់ថា " សួរស្តី ! តើសុខសប្បាយទេ? " ឬក៏ ពាក្យរាក់ទាក់ដទៃទៀត ។ អ្នកផ្សេងទៀតចូលមកដោយចងចិញ្ចើម ឬក៏ មានទឹកមុខមិនសប្បាយ ។ មនុស្សនេះមិនគួរនិយាយកិច្ចការល្អ១ក្នុងការឆ្លើយតបទៅនឹងពាក្យរាក់ទាក់របស់មនុស្សទីមួយនោះទេ ។ បន្ទាប់មកពួកគេចេញពីបន្ទប់នោះ ។

ប្រាប់សិស្សម្តងទៀតអោយកត់ចូលអ្វីដែលពួកគេបានឃើញកើតឡើង ។ កុំអនុញ្ញាតិអោយការពិភាក្សា ឬក៏ការនិយាយស្តីណាមួយអំពីចំនុចនេះ ។ នៅពេលដែលពួកគេបញ្ចប់របាយការណ៍របស់ពួកគេ សូមអោយមនុស្សម្នាក់១អាននូវរបាយការណ៍របស់ពួកគេ ។ ពិតណាស់របាយការណ៍នឹងប្រហាក់ប្រហែលគ្នា ប៉ុន្តែគ្មានរបាយការណ៍ណាមួយដូចគ្នាបេះបិតនោះទេ តាំងពីពាក្យចាប់ផ្តើមដំបូងរហូតដល់ពាក្យដែលគេប្រើដើម្បីបញ្ចប់នោះ ។

ប្រើរបាយការណ៍របស់ពួកគេដើម្បីចង្អុលបង្ហាញចំនុចដែលថា ព្រះជាម្ចាស់បានប្រើមនុស្សផ្សេង១គ្នាជាច្រើនអោយសរសេរកណ្ឌគម្ពីរទាំង ៦៦ កណ្ឌ នៅក្នុងព្រះគម្ពីរ ។ ថ្ងៃនេះយើងនឹងមើលពីរបៀបដែលព្រះជាម្ចាស់បានសំរេចនៅកិច្ចការនេះយ៉ាងរៀបរយ ។

## ៥. ព្រះវិញ្ញាណបំភ្លឺអោយតែង ‑ តើមានអត្ថន័យយ៉ាងដូចម្តេច? (៥‑១០នាទី)

គោលបំណង ទី ១ របស់អ្នកដើម្បីជួយអោយពួកគេយល់អោយបានច្បាស់លាស់នូវពាក្យថា " ព្រះវិញ្ញាណបំភ្លឺអោយតែង " មានអត្ថន័យយ៉ាងដូចម្តេច? អោយសិស្សម្នាក់បើកវចនានុក្រមមើល និង អានអត្ថន័យពាក្យនេះ ។

ព្រះវិញ្ញាណបំភ្លឺអោយតែង : ( វចនានុក្រមអន្តរការីរបស់ វិបស្ទ័រ )

(១) ការកែប្រែ ,ការដឹកនាំ ,ឬទំនាក់ទំនងដោយអំណាចរបស់ព្រះជាម្ចាស់ ឬក៏ ឥទ្ធិពលហួសនិស្ស័យធម្មជាតិ <ព្យាការីត្រូវបានដឹកនាំបំភ្លឺដោយព្រះជាម្ចាស់> <គំនិតត្រូវបានដឹកនាំបំភ្លឺដោយព្រះជាម្ចាស់>

(២ក) ការធ្វើអោយមានជីវិត, ភាពរស់រវើកឡើង, ឥទ្ធិពលលើការសរសេរតម្កើង < មាតារបស់ពួកគេ >

(២ខ) ការមានឥទ្ធិពលលើ < កុមារដែលញ៉ាំងអោយគាត់មានបំណងប្រាថ្នាចង់ទទួលការអប់រំ >

(២គ) បញ្ចូល ឬក៏ ណែនាំអោយស្គាល់នៅក្នុងគំនិត : ការដាស់តឿន < បង្កើតអោយមានទំនុកចិត្តក្នុងអ្នកដើរតាមគាត់ >

ផ្តល់នូវការពន្យល់បង្ហាញជាច្រើនអំពីរបៀប ដែលយើងប្រើពាក្យនេះ នៅក្នុងការសន្ទនាជាធម្មតារបស់យើងសព្វថ្ងៃនេះ ។

- សម្រស់នៃព្រះអាទិត្យរៀបអស្តង់គត ទាក់ទាញចិត្តដល់វិចិត្រករឱ្យគូរ ។
- មេដឹកនាំនយោបាយ ជំរុញចិត្តដល់ហ្វូងមនុស្សដោយពាក្យអត្ថាធិប្បាយដ៏មានអំណាចរបស់គាត់ ។
- ការអានសៀវភៅជំរុញទឹកចិត្តមនុស្សជំទង់ដើរតាមជំហ៊ានរបស់វិរបុរសពួកគេ ។

នៅពេលដែលយើងនិយាយថាព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបំភ្លឺអោយមនុស្សតែងកណ្ឌ័ព្រះគម្ពីរ តើយើងមានន័យយ៉ាងដូចម្តេច? យើងកំពុងតែនិយាយអំពីអ្វីៗដែលពិសេស-ខុសគ្នាទៅនឹងព្រះអាទិត្យអស្តង់គត, អ្នកដឹកនាំនយោបាយ, ឬក៏ សៀវភៅ ។

## ៦. ព្រះវិញ្ញាណបំភ្លឺអោយតែងព្រះគម្ពីរ (៥-១០នាទី )

អោយសិស្សស្វែងរក និង អាន ២ ធីម៉ូថេ ៣:១៦ និង ១ ពេត្រុស ១:២០-២១ ។ ប្រសិនបើអាចធ្វើទៅបានសូមអានអត្ថបទគម្ពីរដែលមានការបកប្រែផ្សេងៗគ្នានៃព្រះគម្ពីរ ។ សូមមើលទំព័រ ទី ៨ ក្នុង សៀវភៅណែនាំរបស់សិស្សសំរាប់ពត៌មានបន្ថែមនៅលើចំនុចនេះ ។

សង្ខេបការស្វែងរករបស់អ្នកដោយផ្តល់ដល់ពួកគេនូវនិយមន័យនៃការបំភ្លឺខាងព្រះគម្ពីរ ដែលផ្តល់ជូននៅ ទំព័រ ទី ៩ នៃសៀវភៅណែនាំរបស់សិស្ស ។

នៅពេលដែលយើងនិយាយថា " ព្រះគម្ពីរត្រូវបានបំភ្លឺអោយតែងដោយព្រះជាម្ចាស់ " យើងមានន័យថា : **ព្រះវិញ្ញាណដ៏វិសុទ្ធបានដឹកនាំគំនិតមនុស្សឱ្យពួកគេសរសេរនូវអ្វីដែលព្រះចង់ឱ្យពួកគេសរសេរ ។**

## ៧. ដាក់ពាក្យថា ព្រះវិញ្ញាណបំភ្លឺអោយតែងនៅក្រដាសមួយដ៏ធំ

ដាក់និយមន័យខាងព្រះគម្ពីរនៃពាក្យនេះ ពីទំព័រ ទី ៩ ក្នុងសៀវភៅណែនាំរបស់សិស្សនៅលើក្រដាសមួយដ៏ធំ និងផ្ទួរវានៅក្នុងថ្នាក់របស់អ្នកដែលអ្នកអាចបង្ហាញពីនិយមន័យនោះជាច្រើនដងនៅក្នុងថ្នាក់រៀនបាន ។

បញ្ជាក់ទៅលើចំនុចដែលបានធ្វើនៅលើទំព័រ ទី ៨ ក្នុងសៀវភៅណែនាំរបស់សិស្ស ។ មានសារៈសំខាន់ណាស់ដើម្បីកត់សំគាល់ថា ព្រះគម្ពីរត្រូវបានព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង ។ គ្រប់ទាំងកណ្ឌ័គម្ពីរទាំងអស់ត្រូវបានជំរុញដោយព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែងស្មើៗគ្នា។ គ្មានកណ្ឌ័គម្ពីរណាមួយត្រូវបានបំភ្លឺអោយតែង ដោយព្រះវិញ្ញាណដែលព្រះជាម្ចាស់ប្រទានមកច្រើនជាងកណ្ឌ័គម្ពីរមួយណាទៀតនោះទេនៅក្នុងព្រះគម្ពីរ ។

## ៨. តើព្រះជាម្ចាស់បានប្រទានព្រះវិញ្ញាណមកបំភ្លឺអោយមនុស្សតែងកណ្ឌ័គម្ពីរដោយរបៀបណា? (១០-២០នាទី)

បង្រៀន បី ចំនុចនៅលើទំព័រ ទី ៩-១០ ក្នុងសៀវភៅណែនាំរបស់សិស្សដែលពន្យល់ពីរបៀបព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺអោយមនុស្សតែងកណ្ឌ័ព្រះគម្ពីរ ។ នៅពេលដែលពិភាក្សាចំនុច ទី ៣ " ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្តល់គំនិតដល់ពួកគេ ដែលអ្នកតែងបានបង្ហាញអោយឃើញទៅតាម មធ្យោបាយផ្ទាល់ខ្លួនរបស់ពួកគេ " យោងទៅសកម្មភាពបើកចំហររបស់ថ្នាក់រៀន ។

សូមចង្អុលបង្ហាញថាអ្នកតែងម្នាក់ៗនៅក្នុងព្រះគម្ពីរមានវិធីនៃការតែងរបស់ពួកគេផ្ទាល់ខ្លួន ។ ប៉ុន្តែព្រះជាម្ចាស់បានដឹកនាំគំនិតរបស់ពួកគេ ធ្វើដូច្នេះពួកគេមិនអាចបញ្ចូលពតិមានមិនត្រឹមត្រូវ ដែលព្រះជាម្ចាស់មិនចង់មាននៅក្នុងព្រះគម្ពីរនោះទេ ។

## ៩. តើកណ្ឌ័គម្ពីរដំបូងត្រូវបានសរសេរឡើងដោយរបៀបណា? (៥-១០នាទី )

នៅទំព័រ ទី ១០ ក្នុងសៀវភៅណែនាំរបស់សិស្សផ្តល់នូវពតិមានជាមូលដ្ឋានដើម្បីបង្រៀននៅទីនេះ ។ សូមធ្វើការពន្យល់នូវចំនុចនេះអោយច្បាស់ថា គ្រប់ទាំងការចំលងរបស់កណ្ឌ័ព្រះគម្ពីរដំបូងបាត់បង់អស់ទៅហើយ ។ សព្វថ្ងៃនេះយើងគ្រាន់តែមានការចំលងនៃកណ្ឌ័គម្ពីរចាស់ៗតែប៉ុណ្ណោះ ។

## ១០. តើគណ្ឋីគម្ពីរត្រូវបានចំលងដោយរបៀបណា? (៥-១០នាទី )

សូមបង្ហាញពត៌មាននៅ ទំព័រ ទី ១០ ក្នុងសៀវភៅណែនាំរបស់សិស្ស នៅក្រោមចំនុច រង លេខ ២ " *តើគណ្ឋីគម្ពីរត្រូវបានចំលងដោយរបៀបណា?* " ប្រសិនបើអាចធ្វើទៅបាន សូមនាំយកនូវរូបភាពរបស់សៀវភៅបុរាណដែលត្រូវបានប្រើនោះ ។ មានសៀវភៅជាច្រើនដែលអាចរកបានសព្វថ្ងៃនេះនៅក្នុងសៀវភៅបុរាណដែលនិយាយអំពី សមុទ្រស្លាប់ ។ សព្វវចនាធិប្បាយភាគច្រើននឹងមានពត៌មាននៅលើសៀវភៅបុរាណនេះ ។

អ្នកអាចផ្តល់ដល់ពួកគេ នូវពត៌មានបន្ថែមខ្លះៗទៀត នៅលើច្បាប់សំរាប់អ្នកសរសេរត្រូវធ្វើតាមនៅពេលចំលងកណ្ឋីគម្ពីរ។ សូមកត់សំគាល់ថា នៅក្នុងមេរៀនបន្ទាប់ទៀតនៅ ជំពូក ទី ៣ និយាយអំពី " *តើខ្ញុំអាចដឹងថាព្រះគម្ពីរពិតត្រឹមត្រូវដោយរបៀបណា?* " មានចំនុចមួយនិយាយពី សៀវភៅបុរាណនិយាយអំពីសមុទ្រស្លាប់ ។ អ្នកអាចរងចាំរហូតដល់អ្នកបង្រៀនមេរៀននោះ ដើម្បីប្រាប់នូវចំនុចនេះ ប្រសិនបើអ្នកមិនមានពេលវេលាគ្រប់គ្រាន់នៅថ្ងៃនេះទេ ។

នៅទំព័រ ទី ៨-១១ ក្នុងសៀវភៅ *យល់ដឹងពីព្រះគម្ពីររបស់អ្នក* ក៏មានពត៌មានផងដែរនៅលើចំនុចខ្លះៗនៃការបកប្រែដំបូងនៃព្រះគម្ពីរ ។ សូមចង្អុលបង្ហាញថា អ្នកបកប្រែសព្វថ្ងៃនេះមានសៀវភៅសរសេរដោយដៃចាស់ៗជាច្រើនជាភាសាក្រិក និង ភាសាហេប្រឺរាប់រយដើម្បីប្រើនៅពេលដែលពួកគេចាប់ផ្តើមធ្វើការបកប្រែថ្មីនៃព្រះគម្ពីរនោះ ។

## ១១. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥-១០នាទី )

សំរាប់ការអនុវត្តន៍ផ្ទាល់ខ្លួនថ្ងៃនេះ រំលឹកឡើងវិញម្តងទៀតនូវសេចក្តីពិតនៃព្រះគម្ពីរ និង ខ គម្ពីរសំខាន់ៗសំរាប់មេរៀននេះ ។ សូមលើកទឹកចិត្តរបស់ពួកគេអោយធ្វើការប្តេជ្ញាចិត្តដើម្បីដាក់សេចក្តីទុកចិត្តនៅលើព្រះគម្ពីរ និង ទទួលយកព្រះគម្ពីរថា ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនមែនគ្រាន់តែចាត់ទុកថាព្រះគម្ពីរគឺជាគំនិតល្អៗរបស់ជនជាតិយូដាដែលបានសរសេរនោះទេ ។

សូមលើកទឹកចិត្តពួកគេអោយស្វែងរកវិធីដ៏មានប្រយោជន៍ដើម្បីចាប់ផ្តើមប្រើការបង្រៀនរបស់ព្រះគម្ពីរនៅក្នុងជីវិតរបស់ពួកគេនៅថ្ងៃនិមួយៗ ។

## ១២. កិច្ចការដែលត្រូវធ្វើ

ក. ផ្តល់នូវសំនួរខ្លីៗ ២ នៅលើ ព្រះគម្ពីរដំណឹងល្អតាមរយៈសំបុត្ររបស់លោក ប៉ូល

ខ. ដាក់ពិន្ទុគំរោង ទី ២ និង ទី ៣

គ. អោយសិស្សអានទំព័រ ទី ៨-១០ ក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីរំលឹកឡើងវិញនូវប្រធានបទដែលត្រូវបានពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

ឃ. អោយសិស្សអានទំព័រ ១១-១៤ ក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីរៀបចំ សំរាប់វគ្គសិក្សាពេលក្រោយ ។

## ១៣. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង?តើចំនុចមួយណាមើលទៅវាមានប្រយោជន៏ដល់សិស្ស របស់អ្នក ?

# មេរៀន ទី ៣

## តើព្រះគម្ពីរពិតត្រឹមត្រូវឬទេ?

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែបង្ហាញភស្តុតាងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្ញុំថាការបង្រៀនរបស់ព្រះគម្ពីគឺជាសេចក្តីពិត ។

### ២. ខ គម្ពីរសំខាន់ : ម៉ាកុស ៤:២៤

ព្រះយេស៊ូមានព្រះបន្ទូលទៀតថា : ចូរអ្នករាល់គ្នាប្រុងប្រយ័ត្ននឹងសេចក្តីណា ដែលអ្នករាល់គ្នា ស្តាប់នេះអោយមែនទែន ។ ព្រះជាម្ចាស់នឹងវាល់អោយអ្នករាល់គ្នាតាមរង្វាល់ដែលអ្នករាល់គ្នាអោយអ្នកដទៃ ហើយព្រះអង្គបន្ថែមអោយអ្នករាល់គ្នា ។

### ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ១១-១៤ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។

### ៤. ការចាប់ផ្តើមមេរៀន : ល្បែងសំដែងខ្លីៗ របស់បុរសស្រេកទឹក (៥នាទី)

មុនពេលចាប់ផ្តើម សូមជ្រើសរើស អ្នកចូលរួមលេងឆាកសំដែងនេះពីរនាក់ ។យកការទឹកដូចគ្នាពីរមកក្នុងថ្នាក់ ។ សូមដាក់ទឹកចូលកាទាំងពីរនោះ ។

អោយមនុស្សទី ១ រៀបការមានទឹកទាំងពីរនៅលើតុ និង ពន្យល់ថា តើគាត់កំពុងធ្វើអ្វីជាមួយនឹងទឹកក្នុងការណ៍នោះ ។ ការទឹកមួយមានទឹកសុទ្ធ និង ការទឹកមួយទៀតយើងនឹងដាក់ថ្នាំពុល ។ នៅក្នុងការទឹកមួយ យើងដាក់ថ្នាំពុលមួយដំណក់ ឬពីរ ដំណក់ ។ ថ្នាំពុលយើងអាចយកជាតិអាកុលមកធ្វើជាថ្នាំពុល ។

គាត់គួរតែអានអោយខ្លាំងៗនៅលើ ផ្លាកសញ្ញាដែលមានជាតិអាកុលដែលប្រាប់មិនអោយផឹក ។គាត់នឹងបង់លេខនៅលើការនិមួយៗ ដូច្នេះគាត់ដឹងថា ការមួយណាមានជាតិពុល ។ ឥឡូវនេះបុរសនោះអង្គុយ ជិតការទឹក ហើយអានទស្សនាវដ្តី ។

ឥឡូវនេះមនុស្សទីពីរ មកពីខាងក្រៅថ្នាក់រៀន ចូលមកក្នុងថ្នាក់ហើយនិយាយថា :"ខ្ញុំស្រេកទឹក។ តើលោកមានភេសជ្ជ:ណា សំរាប់ខ្ញុំញុំាបានទេ ? "

" បាទ មាន" ខ្ញុំមានការទឹកពីរនៅទីនេះ ។ ការមួយមានទឹកសុទ្ធ ហើយមួយទៀតមាន ថ្នាំពុល។

ប្រសិនបើលោក ស្រេកទឹក សូមយកពិសារខ្លួនឯងចុះ " ។ ហើយបន្ទាប់ មកគាត់ក៏លើកទស្សនាវដ្ដីមកអានបន្ត ទៅទៀត ។

បុរសដែលស្រេកទឹកនោះ មានការស្ទាក់ស្ទើរ បន្ទាប់ពីលើកការទឹកទាំងពីនោះ ហើយមើលវាដោយប្រុងប្រយ័ត្ន ។ ហើយក៏និយាយថាៈ " អ្នកនិយាយលេងទេ! តើមែនទេ? តាមពិតវាគ្មានថ្នាំពុលទេនៅក្នុងទឹកនេះមិនអញ្ចឹង " ?

បុរសនោះនិយាយថា " ទេ!ខ្ញុំមិននិយាយលេងទេ " ការទឹកទាំងពីរនោះមានការមួយមានថ្នាំពុល ។ ខ្ញុំដឹង ពីព្រោះខ្ញុំដាក់ថ្នាំពុលដោយខ្លួនឯង។ "ប៉ុន្តែការណ៍ទឹកមួយទៀតនោះមានទឹកសុទ្ធដ៏ឆ្ងាញ់ពិសារ! ខ្ញុំឮថាអ្នកស្រេក ទឹក មែនទេ? សូមយកពិសារចុះ ។ "

បុរសដែលស្រេកទឹកនោះនិយាយថា : " តើខ្ញុំដឹងថាអ្នកនឹងប្រាប់ខ្ញុំនូវការពិតដោយរបៀបណា? " ប្រហែល ជាអ្នកដាក់ថ្នាំពុលទាំងពីរ ។ តើអ្នកអាចប្រាប់នូវការពិតឱ្យខ្ញុំបានដឹងបានទេ បើខ្ញុំសួរអ្នកថា មួយណាដែលអាច ញ៉ាំបាននោះ ? ប្រហែលជាអ្នកមានជំងឺធ្ងន់ធ្ងរហើយ និង ចូលចិត្តមើលមនុស្សស្លាប់ ដោយវិធីរបៀបហ្នឹង ។

មនុស្សទី ១ បានដាក់ទស្សនាវដ្ដីរបស់គាត់ចុះហើយនិយាយថា : " ខ្ញុំមិនឈឺធ្ងន់ទេ ហើយជាមនុស្សដែល គួរអោយទុកចិត្ត ។ ខ្ញុំធ្វើដូច្នេះដើម្បីបង្រៀនសិស្សនូវមេរៀនដ៏សំខាន់មួយ ។ ខ្ញុំមិននិយាយកុហកទេ ។ ខ្ញុំមិន ចង់ឃើញអ្នកញ៉ាំថ្នាំពុលទេ ។ ហេតុដូច្នេះហើយបានជាខ្ញុំបានប្រាប់អ្នកថា ការទឹកមួយមានថ្នាំពុល ។ បើអ្នកចង់ញ៉ាំ ខ្ញុំគិតថាអ្នកត្រូវតែទុកចិត្តខ្ញុំ ។ ពេលនោះគាត់លើកការទឹកសុទ្ធឡើង ហើយនិយាយថា : នែ៎! ញ៉ាំទឹកមួយនេះទៅ ។ ទឹកមួយនេះអាចញ៉ាំបាន ។ " បន្ទាប់មកអោយគេទាំងពីរនាក់មកខាងមុខ ។

## ៥. ការផ្លាស់ប្តូរពីរឿងល្ខោនខ្លីៗទៅមេរៀន (២-៥នាទី )

យើងទាំងអស់គ្នាត្រូវការទឹក បើសិនជាយើងចង់អោយមានជីវិតខាងសរីរាង្គកាយរបស់យើង ។ ប៉ុន្តែបើសិនជា យើងចង់បានជីវិតខាងព្រះវិញ្ញាណដែលនឹងឋិតនៅអស់កល្បនោះ នោះយើងត្រូវតែសុខចិត្តនិងទុកចិត្តលើព្រះអង្គ នៅពេលទ្រង់មានព្រះបន្ទូលថា " ទុកចិត្តលើខ្ញុំ ខ្ញុំមានជីវិតដើម្បីផ្តល់អោយអ្នក ។ ព្រះគម្ពីរដែលជាព្រះបន្ទូល របស់ខ្ញុំពេញទៅដោយសេចក្តីពិត ។ អ្នកអាចជឿលើព្រះបន្ទូល ។ សូមដាក់សេចក្តីទុកចិត្តរបស់អ្នកនៅក្នុង ព្រះគម្ពីរ ។

ប៉ុន្តែពួកយើងភាគច្រើនសួរថា : " តើខ្ញុំអាចដឹងថា ព្រះគម្ពីរជាសេចក្តីពិតដោយរបៀបណា? តើយើងដឹងថា ព្រះគម្ពីរមិនកែប្រែយ៉ាងដូចម្តេចបាន? ប្រហែលជាវាខុសទាំងអស់ ។ តើអ្នកអាចបង្ហាញភស្តុតាងថា មនុស្ស មិនបានកែប្រែ ឬក៏ ផ្លាស់ប្តូរព្រះគម្ពីរនោះទេ?

គោលបំណងសំខាន់នៃមេរៀននេះគឺចង់ស្វែងរកភស្តុតាងដែលគួរអោយជឿទុកចិត្តបានដែលថា ព្រះគម្ពីរដែល យើងមានសព្វថ្ងៃនេះគឺពិតត្រឹមត្រូវ ។

## ៦. គ្រប់ទាំងព្រះបន្ទូលថ្លែងទុកទាំងអស់ពិត និងត្រឹមត្រូវៈ ព្រះបន្ទូលថ្លែងទុកនៅក្នុងសញ្ញាចាស់ (៥-១០នាទី)

មុនដំបូង ពន្យល់ថាតើព្រះបន្ទូលថ្លែងទុកមានអត្ថន័យយ៉ាងដូចម្តេច ។ សៀវភៅណែនាំរបស់សិស្សបានផ្តល់ នូវនិយមន័យ ដូចខាងក្រោម ។

១) សារមកពីព្រះជាម្ចាស់ដែលនិយាយដោយគ្រីស្តបរិស័ទ

២) ការប្រាប់អ្វីនឹងកើតឡើង -សារមកពីព្រះជាម្ចាស់ដែលប្រាប់អ្វីនឹងកើតឡើងនៅក្នុងអនាគតខាងមុខ

សូមមើលទំព័ ទី ១១ ក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីជាពត៌មានបន្ថែមទៅលើចំនុចនេះ ។ អោយសិស្ស បើកព្រះគម្ពីរសញ្ញាចាស់ និង ស្វែងរកព្រះបន្ទូលថ្លែងទុក និង កន្លែងដែលនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែលបានកើត ឡើងរួចទៅហើយនោះ ។ សូមចង្អុលបង្ហាញថា សៀវភៅបុរាណដែលនិយាយអំពីសមុទ្រស្លាប់ខ្លះបានបង្ហាញនូវ ភស្តុតាងថាត្រូវបានសរសេរប្រហែលច្រើនជាង ២០០ ឆ្នាំ មុនព្រះយេស៊ូប្រសូត្រ ។ ដូច្នេះយើងដឹងថា ព្រះបន្ទូលថ្លែងទុកនេះត្រូវបានសរសេរឡើងមុននឹងត្រូវបានបំពេញ ។

## ៧. គ្រប់ទាំងព្រះបន្ទូលថ្លែងទុកទាំងអស់ពិត និងត្រឹមត្រូវៈ ព្រះបន្ទូលថ្លែងទុកនៅក្នុងសញ្ញាថ្មី (៥-១០នាទី )

គម្ពីរដំណឹងល្អក៏មានព្រះបន្ទូលថ្លែងទុកផងដែរដែលត្រូវបានបំពេញដោយការសុគត និង រស់ឡើងវិញរបស់ព្រះ យេស៊ូ ។ អ្នកអាចមានសៀវភៅអក្សរសាស្ត្របន្ថែមទៀត ដែលបង្ហាញថាគ្មានសល់នៅព្រះបន្ទូលថ្លែងទុកដែល គ្មានសេសនោះទេ គ្រប់ទាំងព្រះបន្ទូលថ្លែងទុកនៅក្នុងព្រះគម្ពីរកើតឡើងពិតរួចទៅហើយ ។ សូមចង្អុលបង្ហាញ គ្មានព្រះបន្ទូលថ្លែងទុកណាមួយបានបង្ហាញថាមិនត្រឹមត្រូវនោះទេ ។

ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា ព្រះគម្ពីរគួរជាទីទុកចិត្តបាន ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចទុកចិត្តបាន។ នៅពេលដែលព្រះគម្ពីរបានបង្ហាញថា មានជីវិតបន្ទាប់ពីសេចក្តីស្លាប់ ហើយយើងជ្រើសរើសឥឡូវនេះថាតើកន្លែងណាយើងនឹងចំណាយពេលវេលាអស់កល្បរបស់យើង យើងចាំបាច់ត្រូវតែផ្តល់នូវគំនិតដ៏ច្បាស់លាស់មួយពីរបៀបយើងនឹងឆ្លើយតប ។

## ៨. ព្រះគម្ពីរចែងថា វាគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ (៣-៥នាទី)

សូមមើលទំព័រ ទី ១២ ក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមាន និង អត្ថបទគម្ពីរដើម្បីប្រើជាមួនឹងចំនុចនេះ ។ ពួកគេចាំបាច់ត្រូវតែយល់ដឹងថា ប្រសិនបើយើងអាចបង្ហាញភស្តុតាងថា ព្រះគម្ពីរមិនមែនជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះយើងអាចប្រងើយកន្តើយចំពោះការបង្រៀនរបស់ព្រះគម្ពីរបាន ។ ប៉ុន្តែព្រះគម្ពីរត្រូវបានបញ្ជាក់បង្ហាញយ៉ាងច្បាស់ថា ជាព្រះគម្ពីររបស់ព្រះជាម្ចាស់មិនមែនជារបស់មនុស្សនោះទេ ។

## ៩. ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ (៥-១០នាទី )

សូមមើលទំព័រទី ១២ ក្នុងសៀវភៅណែនាំរបស់សិស្ស សំរាប់ពតិមាន និង អត្ថបទគម្ពីរដើម្បីប្រើជាមួយនឹងចំនុចនេះ ។ សូមកុំបន្លាយពេលវេលាជជែកគ្នាច្រើនពេកនៅទីនេះ ។ ប៉ុន្តែអ្នកអាចបង្កើនករណីអោយកាន់ តែច្បាស់នៅលើទីបន្ទាល់របស់ព្រះយេស៊ូ ។ ប្រសិនបើគេឃើញទ្រង់ជាមនុស្សបាប ឬក៏ ជាអ្នកកុហក នោះយើងនឹងមិនទទួលថាព្រះគម្ពីរជាសេចក្តីពិតនោះទេ ។ ប៉ុន្តែប្រសិនបើអ្វីដែលទ្រង់មានព្រះបន្ទូលគឺជាសេចក្តីពិតយើងចាំបាច់ត្រូវតែពិចារណាអោយបានច្បាស់លាស់នូវអាកប្បកិរិយារបស់យើងចំពោះអត្ថបទព្រះគម្ពីរ ។

## ១០. គ្មានបដិវាទកម្មនោះទេ នៅក្នុងព្រះគម្ពីរ (ភាពផ្ទុយគ្នា) (៥-១០នាទី )

សូមពន្យល់អ្វីទៅជាបដិវាទកម្មដើម្បីធ្វើអោយប្រាកដថាពួកគេយល់ដឹងពីអ្វីដែលអ្នកកំពុងតែនិយាយនៅទីនេះ ។ សូមមើលទំព័រ ទី ១២-១៣ក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមាននៅលើចំនុចនេះ ។ អ្នកអាចប្រើការពន្យល់បង្ហាញដូចខាងក្រោមពីរបៀបមនុស្សធ្វើកំហុសនៃការបញ្ជូលព្រះគម្ពីរថាមានបដិវាទកម្ម(ភាពផ្ទុយគ្នា) ។

សូមសួរសំនួរនេះដល់សិស្ស : " សូមគិតថាតើមានអ្វីកើតឡើងចំពោះសេចក្តីជំនឿរបស់អ្នកអំពីព្រះជាម្ចាស់ប្រសិនបើខ្ញុំអាចបង្ហាញភស្តុតាងថា " គ្មានព្រះជាម្ចាស់ ។ " អ្នកមិនជឿខ្ញុំឬ? សូមមើល និង អានព្រះគម្ពីរទំនុកតម្កើង ១៤:១ ។ " សូមអោយគេរកមើលខគម្ពីរ និង មើលខ្លួនឯង ។

ពិភាក្សាជាមួយពួកគេនូវបញ្ហាដែលកើតមានឡើងនៅពេលមនុស្សយកតែផ្នែកមួយនៃខគម្ពីរមកមើល ដោយពុំបានយល់នូវអត្ថន័យទាំងមូល ។ " ភាពខុសគ្នា " ជាច្រើនដែលមនុស្សនឹងលើកឡើងនោះអាចត្រូវបានពន្យល់ដោយមើលយ៉ាងប្រុងប្រយត្ន័នៅអ្វីដែលព្រះគម្ពីរចែងអំពីបញ្ហានោះ ។

អោយសិស្សរបស់អ្នកប្រុងប្រយត្ន័អំពីបញ្ហាដទៃទៀតនៅទីនេះ ។ មនុស្សភាគច្រើនដែលជឿថា ព្រះគម្ពីរមានបដិវាទកម្មនឹងនិយាយថា " ព្រះគម្ពីរមានបដិវាទកម្មទៅនឹងអត្ថន័យនៅក្នុងព្រះគម្ពីរខ្លួនឯង ។ " ពួកគេនឹងបន្តនិយាយប្រាប់អ្នកនូវ " បដិវាទកម្មនេះ ។ " ប្រាប់សិស្សរបស់អ្នកអោយសួរមនុស្សនោះអោយប្រាប់កណ្ឌ័គម្ពីរ, ជំពូក និង ខ នៅក្នុងព្រះគម្ពីរដែលមានភាពផ្ទុយគ្នានោះ ។ មនុស្សជាច្រើនមិនមានសេចក្តីបញ្ជាក់នោះទេ ។ ប្រាប់ពួកគេអោយពិនិត្យមើលឡើងវិញនូវអ្វីដែលព្រះគម្ពីរចែង ។

## ១១. ការបង្ហាញភស្តុតាងខាងបុរាណវិទ្យា (១០_១៥នាទី )

ប្រធានបទនេះមាននៅក្នុងសៀវភៅណែនាំរបស់សិស្សក្នុងទំព័រ ទី ១៣ ។ អ្នកអាចយកសៀវភៅខ្លះៗទៀតមកក្នុងថ្នាក់ដែលទាក់ទងទៅនឹងប្រធានបទនេះ ។ ភស្តុតាងនៅក្នុងសៀវភៅនេះ គឺមានលើសពីការស្មាន ។ សៀវភៅបុរាណនិយាយអំពី សមុទ្រស្លាប់គឺជាការរកឃើញសំខាន់បំផុតនៅក្នុងសតវត្សទី ២០ ។ អ្នកប្រហែលជាបានពិភាក្សារួចទៅហើយអំពី សមុទ្រស្លាប់នេះនៅក្នុងមេរៀនដំបូងរបស់អ្នកនៅក្នុងមុខវិជ្ជានេះ ។

យករូបភាពនៃសៀវភៅបុរាណទាំងនេះអោយសិស្សរបស់អ្នកពិនិត្យមើល ។ សព្វវចនាធិប្បាយជាច្រើនជាពិសេសសព្វវចនាធិប្បាយនិយាយអំពីព្រះគម្ពីរមានរូបភាពទាំងនេះ ។ ប្រសិនបើអ្នកមិនមាន សូមសួរគ្រូគង្វាលរបស់អ្នក ឬក៏ រកមើលនៅបណ្ណាល័យក្នុងតំបន់ ។

## ១២. ការបង្ហាញភស្តុតាងខាងពេទ្យ ( ៥_១០នាទី )

សូមមើលទំព័រទី ១២ នៃសៀវភៅណែនាំរបស់សិស្ស ដើម្បីជាពត៌មានបន្ថែមនៅលើចំនុចនេះ ។ សៀវភៅមួយមានចំណងជើងថា *គ្មានជំងឺទាំងនេះ* ដែលបានសរសេរដោយលោក មីលែន ជាវេជ្ជបណ្ឌិត បានផ្តល់នូវពត៌មានយ៉ាងអស្ចារ្យនៅក្នុងវិស័យពេទ្យនេះ ។ សូមចែកចាយឧទាហរណ៍ ពីរ ឬក៏ ច្រើនពីសៀវភៅនេះដើម្បីបង្ហាញពីរបៀបដែលព្រះជាម្ចាស់បានផ្តល់អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយនូវច្បាប់ខាងពេទ្យនៅក្នុងព្រះគម្ពីរដែលត្រឹមត្រូវនៅក្នុងវិជ្ជាពេទ្យសព្វថ្ងៃនេះ ។

សូមចង្អុលបង្ហាញពីអារិយធម៌ខ្ពង់ខ្ពស់ជាច្រើននៅក្នុងសម័យនោះមានច្បាប់ខាងពេទ្យដែលមិនមានសុវត្ថិភាព និង បណ្តាលអោយស្លាប់ មិនមែនជាពីជំងឺនោះទេ ។ សូមសរសេរមកកាន់ការិយាល័យរៀបចំកម្មវិធីសិក្សារបស់យើងខ្ញុំ ប្រសិនបើអ្នកចង់ជាវនូវសៀវភៅនេះ ។

## ១៣. បង្ហាញដល់ខ្លួនអ្នកថាព្រះគម្ពីរជាសេចក្តីពិត ដោយសាកល្បងការបង្រៀនរបស់ព្រះគម្ពីរនៅក្នុងជីវិតផ្ទាល់របស់អ្នក (៥-១០នាទី )

នេះប្រហែលជាការសាកល្បងមួយដ៏មានអំណាចបំផុត ដែលអាចត្រូវបានប្រើដើម្បីបង្ហាញ ពីភាពពិតត្រឹមត្រូវរបស់ព្រះគម្ពីរ ។ មានការសាកល្បងផ្សេងៗដទៃទៀតគឺជាកិរិតខាងអ្នកចេះដឹងខ្ពង់ខ្ពស់ ។ ប៉ុន្តែការសាកល្បងមួយនេះគឺជាលក្ខណៈផ្ទាល់ខ្លួន ។

សូមផ្តល់នូវឧទាហរណ៍ផ្ទាល់ខ្លួនជាច្រើនរបស់អ្នក ដែលឧទាហរណ៍នោះអាចជាឧទាហរណ៍របស់អ្នកផ្ទាល់ឬក៏ឧទាហរណ៍របស់គ្រីស្តបរិស័ទដទៃទៀត ដែលអ្នកស្គាល់ ។ សូមបង្ហាញពីរបៀបបង្រៀនដ៏ជាក់លាក់ នៅក្នុងព្រះគម្ពីរដែលបានបង្ហាញភស្តុតាងយ៉ាងពិតប្រាកដនៅក្នុងជីវិតរបស់អ្នក ។ សូមកុំគ្រាន់តែប្រើសេចក្តីពិតនៃព្រះគម្ពីរទូទៅខ្លះៗនោះ ។ សូមអោយមានភាពជាក់លាក់ច្បាស់លាស់ ។

លើកទឹកចិត្តអ្នកដទៃទៀតនៅក្នុងថ្នាក់ដើម្បីចែកចាយឧទាហរណ៍ផ្ទាល់ខ្លួន ពីរបៀបដែលពួកគេបានបង្ហាញភស្តុតាងការបង្រៀនខាងព្រះគម្ពីរនៅក្នុងជីវិតរបស់ពួកគេ ។

អ្នកអាចសម្ភាសន៍គ្រីស្តបរិស័ទចាស់ទុំផងដែរ (ឬក៏ អ្នកដែលបានបញ្ចប់នៅក្នុងមជ្ឈមណ្ឌល ប្រសិនបើអ្នកនឹងបង្រៀនមេរៀននេះនៅក្នុងមជ្ឈមណ្ឌល) និង អោយពួកគេផ្តល់នូវឧទាហរណ៍ផ្ទាល់ខ្លួនពីរបៀបដែលពួកគេបានបង្ហាញភស្តុតាងថាព្រះគម្ពីរគឺជាសេចក្តីពិត ។

សូមមើលទំព័រ ទី ១៤នៃសៀវភៅណែនាំរបស់សិស្សសំរាប់ពត៌មាន និង អត្ថបទគម្ពីរបន្ថែមនៅលើចំនុចនេះ ។ ចំនុចមួយដែលយើងចង់បញ្ជាក់អោយច្បាស់នោះគឺថា ព្រះគម្ពីរមិនមែនជាសៀវភៅមន្តអាគមន៍នោះទេ ។ អ្នកមិនមែនគ្រាន់តែលើកខគម្ពីរពីព្រះគម្ពីរ និង ឃើញការអស្ចារ្យកើតឡើងនោះទេ ។

ព្រះគម្ពីរពេញជាមួយនឹងដំបូន្មានដ៏មានប្រយោជន៍សំរាប់ជីវិតរស់នៅប្រចាំថ្ងៃ ។ លូកា ជំពូក ៦ និង រ៉ូមជំពូក ១២ ពេញជាមួយនឹងការបង្រៀនដ៏មានប្រយោជន៍ដែលអាចសាកល្បងនៅក្នុងជីវិត ។ ប៉ុន្តែហេតុផលដែលសំខាន់ដែលព្រះជាម្ចាស់ដាក់ការបង្រៀនទាំងនេះនៅទីនោះគឺដើម្បីជួយមនុស្ស-មិនមែនជាក្លីនិកសាកល្បងព្យាបាលសំរាប់មនុស្សដែលគិតតែពីអាក្រក់ឬក៏ អាត្មានិយមនោះទេ ។

មិនអាចសំរេចបាននោះទេ ក្នុងការទាមទារអោយព្រះជាម្ចាស់បង្ហាញភស្តុតាងថា ទ្រង់គឺជាព្រះពិតដោយធ្វើអ្វីដែលយើងប្រាប់ទ្រង់អោយធ្វើនោះ ។ ទ្រង់គឺជាព្រះជាម្ចាស់-ទ្រង់គឺជាអ្នកគ្រប់គ្រង ។ ប្រសិនបើនរណាម្នាក់ទាមទារធ្វើដូច្នេះ គឺមិនមែនយើងទាំងអស់គ្នានោះទេ គឺព្រះជាម្ចាស់វិញទេដែលទាមទារអោយយើងធ្វើនោះ ។ សូមបង្ហាញថា ការស្តាប់បង្គាប់គឺជាគន្លឹះ ។ ការជំរុញអោយធ្វើអ្វីមួយរបស់យើងក៏មានសារៈសំខាន់ផងដែរ ។

## ១៤. តារាងស្តីអំពីជីវិតមួយទៅជីវិតមួយទៀតក្នុងការសិក្សាជាគំរូ(៥-១០នាទី )

អ្នកនឹងឃើញតារាងស្តីអំពីជីវិតមួយទៅជីវិតមួយទៀត នៅទំព័រទី ២៣នៅក្នុងសៀវភៅណែនាំរបស់គ្រូនេះ ។ គំរូនេះអាចត្រូវបានប្រើដើម្បីអនុវត្តន៍អត្ថបទគម្ពីរ ចំពោះបញ្ហាដែលមនុស្សម្នាក់ កំពុងប្រឈមមុខនៅក្នុងជីវិតរបស់គាត់ ។ អ្នកអាចមើលកិច្ចការនេះជាមួយសិស្សរបស់អ្នក ដោយប្រើឧទាហរណ៍ពីរឬក៏ បីពីជីវិតរបស់អ្នក ។

## ១៥. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី )

**ក.** អ្នកអាចភ្ជាប់ផ្នែកនៃមេរៀននេះជាមួយនឹងសកម្មភាព # ១៣ និង ១២ នៅក្នុងគំរោងផែនការមេរៀននេះ។ លើកទឹកចិត្តសិស្សរបស់អ្នកធ្វើតាមគំរូពីជីវិតមួយទៅជីវិតជាមួយនឹងកន្លែងជាក់លាក់នៅក្នុងជីវិតផ្ទាល់របស់ពួកគេ ។ សូមអោយពួកគេសរសេរនូវលទ្ធផលនៃអ្វីដែលបានកើតឡើងនៅពេលដែលពួកគេអនុវត្តន៍ ខគម្ពីរទាំងនេះនៅក្នុងជីវិតផ្ទាល់របស់ពួកគេ ។

**ខ.** សំនួរមួយទៀត អ្នកអាចផ្តល់ជូនដល់ពួកគេសំរាប់ជាគំនិតបន្ថែម :
តើសេចក្តីពិតនៃព្រះគម្ពីរមានឥទ្ធិពលយ៉ាងណានៅក្នុងជីវិតរបស់ខ្ញុំ សព្វថ្ងៃ? នេះគឺជាគំនិត បីដែលអាចឆ្លើយតបនឹងសំនួរនេះ ។

១. ខ្ញុំទុកចិត្តព្រះគម្ពីរហើយជឿថាព្រះគម្ពីរ ជាព្រះបន្ទូលពិតរបស់ព្រះ ។

២. ខ្ញុំជឿជាក់ថាអ្វីដែលព្រះគម្ពីរបាននិយាយសព្វថ្ងៃនេះ គឺដូចដែលព្រះបានមានបន្ទូលអោយមនុស្ស សរសេរគម្ពីរកាលសម័យមុនដែរ ។

៣. ខ្ញុំត្រូវប្រុងប្រយត្ន័ដើម្បីប្រើអោយបានត្រឹមត្រូវនូវការបង្រៀនរបស់ព្រះគម្ពីរ ក្នុងជីវិតរបស់ខ្ញុំសព្វថ្ងៃនេះ ។

## ១៦. កិច្ចការដែលត្រូវធ្វើ

ក. ផ្តល់សំនួរខ្លីៗនៅលើព្រះគម្ពីរសញ្ញាថ្មីទាំងអស់ និង ចំណងជើងរបស់ផ្នែកនិមួយៗ ។

ខ. ដាក់ពិន្ទុគំរោង ទី ៥

គ. អោយសិស្សអានទំព័រទី ១១-១៤ក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីរំលឹកប្រធានបទ ដែលបានសិក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

ឃ. ឱ្យសិស្សអានទំព័រ១៥-១៧ ក្នុងសៀវវភៅណែនាំរបស់សិស្សដើម្បី រៀបចំសំរាប់វគ្គសិក្សាក្រោយ ។

## ១៧. ការវាយតម្លៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ?

# តារាង

**គំរូនៃការរៀនពីជីវិតមួយទៅជីវិតមួយ**

១. **សរសេរបង្ហាញស្ថានភាពតានតឹង**

សរសេរបង្ហាញស្ថានភាពដែលខ្ញុំយល់ឃើញថាវាងាយស្រួលអោយខ្ញុំមួម៉ៅ, ខឹង, ក្តៅក្រហាយ ឬក៏ ឈឺចាប់ ។

២. **សួរព្រះជាម្ចាស់នៅសំនួរនេះ**

" ព្រះជាម្ចាស់ តើថ្ងៃនេះព្រះអង្គនឹងព្យាយាមបង្រៀនទូលបង្គំអោយធ្វើអ្វី? "

៣. **រកកន្លែងមួយនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកដែលអ្នកចង់រីកចំរើន**

ប្រើ ១ កូរិនថូស ១៣: ៤-៨ ដើម្បីបង្ហាញនូវកន្លែងដែលអាចធ្វើទៅបាន ដែលអ្នកចាំបាច់ត្រូវការរីកចំរើន

៤. **ភ្ជាប់កិច្ចការនេះទៅការសិក្សាព្រះគម្ពីររបស់ខ្ញុំ**

តើព្រះគម្ពីរមានព្រះបន្ទូលយ៉ាងម៉េចអំពីកន្លែងនេះនៃជីវិតរបស់ខ្ញុំដែលខ្ញុំចង់រីកចំរើន?

៥. **រាយបញ្ជីកិច្ចការដែលខ្ញុំអាចសំរេចនៅថ្ងៃនេះ**

ឬក៏ យើងអាចនិយាយថា បង្កើតគោលដៅ ។ សូមជ្រើសរើសគោលដៅមួយ និង ធ្វើវានៅថ្ងៃនេះ ។

៦. **វាយតំលៃនៅលទ្ធផល**

នៅពេលក្រោយ ថ្ងៃដូចគ្នា ឬក៏ ថ្ងៃបន្ទាប់ រំលឹកឡើងវិញនៅអ្វីដែលបានកើតឡើងនៅពេលដែលអ្នកបានព្យាយាមដើម្បីសំរេច គោលដៅដែលអ្នកបានបង្កើត ។

តារាងដូចគ្នានេះត្រូវបានប្រើនៅក្នុងមុខវិជ្ជាដូចខាងក្រោមនៃការសិក្សាជាក្រុមសំរាប់គ្រីស្តបរិសទ័ថ្មី ។

១- ការប្រណិប័តរបស់គ្រីស្តបរិស័ទ នៅមេរៀនទី ២

២- ការលូតលាស់តាមរយៈបរាជ័យ នៅមេរៀនទី ៤

៣- តើខ្ញុំអាចដឹងថា ខ្ញុំជាគ្រីស្តបរិសទ័ដោយរបៀបណា នៅមេរៀនទី៨ &៩

៤- របៀបសិក្សាព្រះគម្ពីរ នៅមេរៀនទី ២

៥- ការរស់នៅរបស់គ្រីស្តបរិស័ទប្រកបដោយជោគជ័យ នៅមេរៀនទី២

# មេរៀន ទី ៤ :

# ខ្លីៗពីគម្ពីរសញ្ញាចាស់ និង សញ្ញាថ្មី

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែប្រើព្រះគម្ពីរដើម្បីជួយដល់ខ្ញុំនៅក្នុងបទពិសោធន៍នៃជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ។

## ២. ខ គម្ពីរសំខាន់ : ២ ធីម៉ូថេ ៣:១៧

ក្នុងគោលបំណងឱ្យអ្នកបំរើរបស់ព្រះជាម្ចាស់មានសមត្ថភាព និង ប្រុងប្រៀបខ្លួនជាស្រេចដើម្បីប្រព្រឹត្តអំពីល្អគ្រប់ជំពូក។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ១៥-១៧ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។

## ៤. គោលបំណងរបស់មេរៀននេះ

នៅក្នុងមេរៀននេះ គោលបំណងដ៏សំខាន់របស់យើងគឺផ្តល់នូវការសង្ខេបខ្លីៗ នៃគម្ពីរសញ្ញាចាស់ និង សញ្ញាថ្មី ។ សិស្សរបស់យើងខ្លះៗមិនយល់ច្បាស់លាស់នូវព្រះគម្ពីរទាំងមូលនោះទេ ។ ប្រសិនបើពួកគេអាចយល់នៅព្រះគម្ពីរទាំងមូលនៅថ្ងៃនេះ នោះប្រាកដជាមានការងាយស្រួលជាងក្នុងការយល់ដឹងពីរបៀបនៃកណ្ឌ័ព្រះគម្ពីរទាំងអស់ស៊ីគ្នាទៅនឹងគំរោងផែនការរបស់ព្រះជាម្ចាស់សំរាប់ពិភពលោក ។ នៅចុងបញ្ចប់នៃមេរៀន អ្នកនឹងមានឱកាសដើម្បីពិភាក្សាអំពីតួនាទី របស់ព្យាការីមាននៅក្នុងអនាគតរបស់យើង។

## ៥. រយៈពេលនៃប្រវត្តិសាស្ត្រពិភពលោក

អ្នកអាច ប្រើរយៈពេលនៃប្រវត្តិសាស្ត្រតាមរបៀបប្រវត្តិពិភពលោកដើម្បីបង្ហាញនូវអ្វីដែលព្រះគម្ពីបានប្រាប់យើងអំពីប្រវត្តិសាស្ត្រនៃពិភពលោក ។ ចំនុចពេលវេលានេះរួមបញ្ចូលទាំង :

- ការបង្កើត
- ព្រឹត្តិការណ៍ដំបូងនៃកំណើតពិភពលោក
- លោកណូអេ និង ទឹកជំនន់
- ការសង់ប៉មនៅ បាបែល

- ការត្រាសហៅ អប្រាហាំ
- យ៉ូសែបនៅក្នុងប្រទេសអេស៊ីប
- ម៉ូសេ ដឹកនាំជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប
- អ៊ីស្រាអែលស្ថិតក្រោមក្រិត្យវិន័យ
- ការគ្រងរាជ្យដាយ :

  ស្តេចសេអ៊ូល

  ស្តេចដាវីឌ

  ស្តេចសាឡូម៉ូន
- ការបែងចែកអ៊ីស្រាអែលជាសញ្ជាតិពីរ
- កំឡុងពេលការឃុំឃាំងក្នុងបាប៊ីឡូន
- ការធ្វើឱ្យជាតិសាសន៍អ៊ីស្រាអែលដូចដើមវិញ
- ភាពស្ងៀមស្ងាត់៤០០ឆ្នាំរវាងគម្ពីរសញ្ញាចាស់និងគម្ពីរសញ្ញាថ្មី
- ជីវិតរបស់ព្រះយេស៊ូ
- ការសង់ឡើងវិញនៃព្រះវិហារនៅក្រុងយេរូសាឡឹម
- ដំណើរបេសកជនរបស់ លោក ប៉ូល
- ព្រឹត្តិការណ៏របស់ពិភពលោកនៅពេលខាងមុខកំណត់ហេតុដែលបានចងក្រងទុកអោយដឹងជាមុនក្នុងគម្ពីរវិវរណៈ ។

សិស្សនៅក្នុងថ្នាក់ទាំងអស់ចូរប្រើដំណើរពេលវេលា ហើយបង្ហាញថាតើកណ្ឌ៏គម្ពីរមួយណាដែលស៊ីគ្នាជាមួយពេលវេលានិមួយៗ ។ វាមិនមែនចាំបាច់មានកាលបរិច្ឆេទពិតប្រាកដទៅលើកណ្ឌ៏គម្ពីរនិមួយៗ ទៅតាមពេលវេលារបស់អ្នកនោះទេ, ប៉ុន្តែយ៉ាងហោចណាស់បង្ហាញអំពីពេលវេលាជាទូទៅនៅពេលដែលកណ្ឌ៏គម្ពីរនោះត្រូវបានសរសេរដាច់ពីគ្នា ។ ពន្យល់ដោយសង្ខេបទៅលើគោលបំណងនៃកណ្ឌ៏គម្ពីរផ្សេងៗគ្នាដែលត្រូវបានរួមបញ្ចូលនៅក្នុងព្រះគម្ពីរ ។

## ៦. ខ្លីៗពីព្រះគម្ពីរសញ្ញាចាស់ (១០-២០នាទី)

នៅទំព័រ ទី១៥ក្នុងសៀវភៅណែនាំរបស់សិស្សបានផ្តល់ពត៌មានមូលដ្ឋានខ្លះៗស្តីអំពីព្រះគម្ពីរសញ្ញាចាស់ដែលត្រូវបានប្រើនៅក្នុងចំនុចនេះ ។ ពន្យល់ដោយសង្ខេបថាតើហេតុអ្វីបានជាពាក្យ " សញ្ញា "ត្រូវបានប្រើដើម្បីពិពណ៌នានៅការបែងចែកដ៏សំខាន់ពីរនៃព្រះគម្ពីរ ។ ១ កូរិនថូស ១០:១១ ផ្តល់នូវការពន្យល់យ៉ាងល្អថាតើហេតុអ្វីបានជាព្រះគម្ពីរសញ្ញាចាស់មានសារៈសំខាន់សំរាប់យើងសព្វថ្ងៃនេះ ។

អ្នកអាចប្រើសៀវភៅ *យល់ដឹងព្រះគម្ពីររបស់អ្នក* ដើម្បីផ្តល់ឱ្យពួកគេនូវគំនិតខ្លីៗដោយសង្ខេបនៃកណ្ឌ័ព្រះគម្ពីរសញ្ញាចាស់ខ្លះៗ ។ នៅទំព័រ ទី ១២-១៨ ក្នុងនោះ ផ្តល់នូវការសង្ខេបយ៉ាងល្អឥតខ្ចោះ នៃកណ្ឌ័គម្ពីរនិមួយៗ ។ នៅទំព័រ ទី ២៥-២៩ នៅក្នុងសៀវភៅនោះដដែលផ្តល់នូវការពិពណ៌នាយ៉ាងសង្ខេបនៃតួអង្គសំខាន់ៗជាច្រើននៅក្នុងព្រះគម្ពីរ ។ អ្នកអាចមើលនូវការពន្យល់ទាំងពីរនេះថាតើហេតុអ្វីបានជាវាមានតំលៃសំរាប់យើងសិក្សាពីជីវិតរបស់មនុស្សទាំងនេះសព្វថ្ងៃនេះ ។

អ្នកអាចពឹងផ្អែកទៅលើសំនួរខ្លះៗមកពីគំរោងផងដែរ ដែលពួកគេបានបំពេញនៅក្នុងការណែនាំការសិក្សាសំរាប់មុខវិជ្ជានេះ ។

សូមបង្ហាញថានៅជំនាន់ព្រះយេស៊ូ ព្រះគម្ពីរដែលពួកគេមានគឺមានតែព្រះគម្ពីរសញ្ញាចាស់ប៉ុណ្ណោះ ។ យើងចាំបាច់ត្រូវតែមានការប្រុងប្រយត្ន័ថា យើងមិនត្រូវបន្ថោកតំលៃនៃព្រះគម្ពីរសញ្ញាចាស់នោះទេ ។ សូមលើកទឹកចិត្តពួកគេអោយអានព្រះគម្ពីរសញ្ញាចាស់នៅក្នុងផ្លូវមួយដែលមិនធ្វើអោយពួកគេធុនទ្រាន់ ។ ភាពផ្សេងៗគ្នាគឺជាចំនុចគន្លឹះនៅទីនេះ ។

សូមលើកទឹកចិត្តពួកគេ អោយអានទាំងគម្ពីរសញ្ញាចាស់ និង សញ្ញាថ្មី និង ផ្លាស់ប្តូរពីប្រភេទអក្សរសាស្ត្រមួយទៅអក្សរសាស្ត្រមួយទៀត ។សូមលើកទឹកចិត្តសិស្សរបស់អ្នកអោយអានកណ្ឌ័គម្ពីរអោយចប់មួយនៅពេលតែមួយជាជាងផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត ឬពីជំពូកមួយទៅជំពូកមួយទៀតនៃកណ្ឌ័គម្ពីរផ្សេងគ្នានោះ ។

## ៧. ការបកប្រែព្រះគម្ពីរ

កណ្ឌ័គម្ពីរខ្លះអាចភាន់ច្រឡំក្នុងការយល់ដឹងអំពីរបៀបបកប្រែព្រះគម្ពីរ ។ លោក **ហ្វី និង ស្ទូវើត**បានសរសេរសៀវភៅមានចំណងជើងថា *របៀបអានតំលៃទាំងអស់របស់ព្រះគម្ពីរ : ការណែនាំឱ្យស្គាល់នូវព្រះគម្ពី,* ដែលផ្តល់ឱ្យយ៉ាងច្បាស់លាស់ពីបញ្ហានេះ ។ សៀវភៅនេះត្រូវបានសរសេរឡើងសំរាប់អ្នកជឿព្រះ ។ ប៉ុន្តែវាប្រហែលជាមានការលំបាក សំរាប់សិស្សរបស់អ្នកខ្លះៗ ។

## ៨. គំនិតខ្លីៗពីសញ្ញាថ្មី (១០-២០នាទី)

បង្រៀនព្រះគម្ពីរសញ្ញាថ្មីនៅក្នុងរបៀបដូចគ្នាដែលអ្នកបង្រៀនព្រះគម្ពីរសញ្ញាចាស់ដែរ ។ សៀវភៅ *យល់ដឹងពីព្រះគម្ពីររបស់អ្នក* មានប្រយោជន៏ណាស់ ។ សូមពិចារណានូវការប្រើសំនួរខ្លះៗពីគំរោងរបស់ពួកគេនៅក្នុងសៀវភៅការណែនាំការសិក្សា ។

## ៩. តួនាទីរបស់ព្រះបន្ទូលថ្លែងទុកនៅក្នុងព្រះគម្ពីរ (៥-១៥នាទី)

ពន្យល់ដោយសង្ខេបថាតើហេតុអ្វីបានជាព្រះជាម្ចាស់ដាក់ព្រះបន្ទូលថ្លែងទុកនៅក្នុងព្រះគម្ពីរ ។ នេះគឺជាចំនុចសំខាន់បំផុតដើម្បីធ្វើការសិក្សានៅក្នុងមេរៀននេះ ។ មានពេលវេលាជាច្រើន ការពិភាក្សាអំពីព្រះបន្ទូលថ្លែងទុកតូវព្យាយាមដោះស្រាយអោយបានលំអិតទាំងអស់នៃព្រឹត្តិការណ៍អនាគត ។ សូមបង្ហាញអោយ ច្បាស់ពីដំបូងថា ព្រះជាម្ចាស់មិនមែនដាក់ព្រះបន្ទូលថ្លែងទុកនៅក្នុងព្រះគម្ពីរសំរាប់អោយយើងអាចទៅ ទស្សន៍ទាយពីអនាគតដូចជាអ្នកទាយសម័យ បច្ចុប្បន្ននេះគេធ្វើនោះទេ ។

ព្រះជាម្ចាស់បានដាក់ព្រះបន្ទូលថ្លែងទុកនៅក្នុងព្រះគម្ពីរមានហេតុផលដូចនេះ :

១-ដើម្បីបង្ហាញអំពីសេចក្ដីពិតរបស់ព្រះគម្ពីរ

២-ផ្ដល់សេចក្ដីសង្ឃឹមដល់គ្រីស្ដបរិស័ទនៅពេលអនាគត ។រ៉ូម ១៥:៤

៣-ជំរុញឱ្យមនុស្សនៅជាប់នឹងព្រះ

៤-ព្រះបន្ទូលថ្លែងទុកមិនត្រូវបានប្រើដើម្បីទាយពីអនាគតនោះទេ

ចូរកត់ចំណាំនូវការឆ្លើយតបរបស់ព្រះយេស៊ូដល់ពេត្រុសនៅពេលដែលគាត់ព្យាយាមសួរព្រះយេស៊ូដើម្បីឱ្យប្រាប់គាត់នៅពេលអនាគត ។ សូមមើលយ៉ូហាន ២១:១៥-២៤ ជាពិសេស ខ ២០-២៣ ។ ចូរកត់ចំណាំផងដែរនូវរបៀបដែលមនុស្សងាយនឹងយល់ខុសអំពីការអធិប្បាយរបស់ព្រះយេស៊ូអំពីអនាគតរបស់លោក យ៉ូហាន ។ យើងក៏អាចមានកំហុសដូចគ្នានេះដែរ បើយើងចាប់ផ្ដើមប្រើព្រះបន្ទូលថ្លែងទុកខុស ។

## ១០. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី)

ប្រើសេចក្ដីពិតសំខាន់ៗនៃព្រះគម្ពីរនៅមេរៀនថ្ងៃនេះដើម្បីបញ្ជាក់ពីតម្រូវការរបស់មនុស្សម្នាក់ៗអោយមានការប្រុងប្រយត្ន័ប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងការដឹកនាំនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ។ព្រះបន្ទូលរបស់របស់ទ្រង់ពោរពេញទៅដោយការលើកទឹកចិត្ត, ការប្រាប់នូវទិសដៅ និង ការប្រាប់អោយដឹងជាមុន ។ ប្រសិនបើយើងគោរព និង ស្ដាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងនឹងឃើញថាទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់នឹងកាន់តែជ្រៅទៅៗ ។

ប៉ុន្តែយើងត្រូវតែចាំថា សេចក្ដីស្រលាញ់ និង ការគោរពដ៏ខ្ពង់ខ្ពស់របស់យើងមិនមែនមានចំពោះសៀវភៅព្រះគម្ពីរនោះទេ គឺសេចក្ដីស្រលាញ់ និង ការគោរពដ៏ខ្ពង់ខ្ពស់របស់យើងគឺសំរាប់អ្នកនិពន្ធ គឺព្រះជាម្ចាស់ផ្ទាល់ ។

## ១១. កិច្ចការដែលត្រូវធ្វើ

ដាក់ពិន្ទុគំរោង ទី ៦ និង គំរោង ផ្សេងៗទៀតដែលពួកគេបានបំពេញរួចហើយដែលគំរោងនោះមិនទាន់បានដាក់ពិន្ទុនៅឡើយ ។

## ១២. ការវាយតម្លៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៏ដល់សិស្សរបស់អ្នក?

# មេរៀន ទី ៥ :

# ការប្រឡង

**១. ណែនាំអោយស្គាល់នូវមុខវិជ្ជាដែលអ្នកនឹងបង្រៀនពេលក្រោយ**

**ក.** អោយសៀវភៅណែនាំរបស់សិស្ស និង ការណែនាំការសិក្សា និង ចាត់ចែងគំរោងដែលត្រូវបំពេញមុនរៀនមេរៀនបន្ទាប់ទៀតដែលអ្នកនឹងត្រូវបង្រៀន ។

**ខ.** អោយសិស្សមើលនៅទំព័រចុងក្រោយនៃសៀវភៅការណែនាំការសិក្សារបស់ពួគេ ។ ពួកគេនឹងឃើញបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់ ។ ផ្តល់នៅកាលបរិច្ឆេទសំរាប់សំនួរខ្លីៗ, គំរោង និង ការប្រលងនិមួយៗ ។

**២. ផ្តល់ការប្រលងនៅលើមុខវិជ្ជានេះ**

**៣. ដាក់ពិន្ទុគំរោង ទី ៨**

**៤. សូមប្រគល់សំនួរខ្លីៗ និង គំរោងដែលអ្នកបានដាក់ពិន្ទុរួចហើយទាំងអស់ដល់សិស្ស ប្រសិនបើអ្នកមិនទាន់បានប្រគល់ជូននៅឡើយនោះ ។**

# ផែនការមេរៀនសំរាប់គ្រូ

សូមពិនិត្យមើល ទំព័រ ទី ១ និង ទី ២ ដែលស្តីអំពី " របៀបប្រើសៀវភៅណែនាំរបស់គ្រូ " ដើម្បីទទួលពត៌មានបន្ថែម អំពីការប្រើផែនការមេរៀន ទាំងនេះ ។